# រឿងរ៉ាវរបស់ស្ត្រីក្រីក្រ
# ក្នុងទីក្រុង

**ការពិត និងតួលេខ #៣៨** **ខែកក្កដា ឆ្នាំ២០១៩**



## ១. ប្រតិបត្តិសង្ខេប

ស្ត្រីក្រីក្រនៅក្នុងទីក្រុងតែងតែដឹកនាំសហគមន៍ក្នុងការទាមទារសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋានរបស់ពួកគាត់។ ទោះជាយ៉ាងណាក៏ដោយ ពួកគាត់ក៏បាន និងកំពុងប្រឈមបញ្ហាជាច្រើនប្រចាំថ្ងៃដោយសារពួកគាត់ជាស្ត្រី។ ការស្រាវជ្រាវនេះនឹងបង្ហាញពីបញ្ហាមួយចំនួនដែលស្ត្រីក្រីក្រនៅទីក្រុងបានប្រឈមនៅក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគាត់។ អនុសាសន៍មួយចំនួននឹងមាននៅចុងបញ្ចប់នៃរបាយការណ៍នេះ ដោយយើងទទួលបានពីស្ត្រីដែលបានចូលរួមក្នុងការសិក្សារបស់យើង។

ស្ត្រីក្រីក្រចំនួន៨នាក់ដែលរស់នៅក្នុងតំបន់ក្រីក្រ និងតំបន់ដែលកំពុងប្រឈមនឹងការគំរាមកំហែងពីការបណ្តេញចេញត្រូវបានសម្ភាសសម្រាប់របាយការណ៍នេះ។ ស្ត្រីមួយចំនួនបាននិយាយថា បរិស្ថានជាផ្នែកមួយនៃមូលហេតុដែលធ្វើឱ្យសុខភាពរបស់ពួកគាត់មិនល្អ ហើយស្ត្រីមួយចំនួនទៀតក៏បានលើកឡើងថា ដោយសារពួកគាត់ជាអាណាព្យាបាល ជាអ្នកទុកដាក់លុយកាក់ និងជាមេគ្រួសារអញ្ចឹងហើយគាត់ត្រូវគិតគូរពីសុខភាពរបស់កូន និងប្តីជាងសុខភាពខ្លួន។

ស្ត្រីទាំងនោះបានប្រាប់ថា ពួកគាត់បានរងនូវការរំលោភបំពានពីសំណាក់ស្វាមី ការមិនទទួលស្គាល់ពីអាជ្ញាធរ និងការរើសអើងពីសហគមន៍ ប៉ុន្តែការភ័យខ្លាចពីការបណ្តេញចេញនៅតែជាបញ្ហាប្រឈមធំបំផុតសម្រាប់ពួកគាត់។ ស្ត្រីខាងលើបានបន្តថា ពួកគាត់មានមោទនភាពចំពោះសហគមន៍របស់គាត់ បើទោះបីជាពេលខ្លះវាបង្កជាជំងឺដល់ពួកគាត់ ដោយសារសហគមន៍ខ្វះអនាម័យ និងមានទឹកលិចជាប្រចាំក៏ដោយ។ ស្ត្រីទាំងនោះមានជំនឿយ៉ាងមុតមាំថា ក្នុងនាមជាមនុស្សគឺពួកគាត់មានសិទ្ធទទួលបានសិទ្ធិមានលំនៅឋានសមរម្យ និងសុវត្ថិភាពដីធ្លី។ នៅពេលដែលស្នើសុំឱ្យស្ត្រីថតរូបអំពីការពេញចិត្ត និងបញ្ហានៅក្នុងជីវិតរបស់ពួកគាត់ ស្ត្រីភាគច្រើនបានថតរូបពីបញ្ហាប្រឈមដែលពួកគាត់ជួបប្រទះនៅក្នុងសហគមន៍របស់ពួកគាត់ ហើយពិបាករកកន្លែងស្អាតសមរម្យនៅក្នុងសហគមន៍របស់ពួកគាត់ណាស់។

## ២. វិធីសាស្ត្រស្រាវជ្រាវ

ការសម្ភាសត្រូវបានធ្វើឡើង ជាមួយស្ត្រីចំនួន៨នាក់ដែលមកពីសហគមន៍ចំនួន៦។ លើសពីនេះទៅទៀតអ្នកស្រាវជ្រាវបានស្នើឱ្យស្ត្រីថតរូបភាពនូវអ្វីដែលជាបញ្ហាប្រឈម និងអ្វីដែលពួកគាត់ពេញចិត្តក្នុងសហគមន៍របស់ពួកគាត់។ ដំណើរការសម្ភាសបានប្រើប្រាស់កម្រងសំណួរពិភាក្សាលើចំនុចសំខាន់ៗដែលស្ត្រីបានប្រឈមនឹងអ្នកស្រាវជ្រាវពិភាក្សាលើបញ្ហាផ្សេងៗទៀតក្នុងពេលសម្ភាស។ លើសពីនេះទៅទៀត ការសម្ភាសនេះតម្រូវឱ្យស្ត្រីមានទំនុកចិត្ត និងមិនទទួលសម្ពាធពីមជ្ឈដ្ឋានជុំវិញក្នុងអំឡុងពេលផ្តល់បទសម្ភាសជាមួយបុគ្គលិករបស់អង្គការសមាគមធាងត្នោត។

ជាចុងក្រោយ អ្នកស្រាវជ្រាវបានប្រមូលព័ត៌មានដែលមានស្រាប់ និងជួបពិភាក្សាជាមួយអង្គការសង្គមស៊ីវិលសំខាន់ៗ និងអង្គការដែលធ្វើការងារទាក់ទងទៅនឹងស្ត្រីក្រីក្រក្នុងទីក្រុងមានដូចជា អង្គការលីកាដូ អង្គការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា និងអង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង។

**តារាងទី១ ៖ អាយុស្រ្តីក្រីក្រដែលបានសម្ភាស**

| អាយុចន្លោះ | ចំនួនអ្នកផ្តល់បទសម្ភាស |
|---|---|
| ១៩-២៥ឆ្នាំ | ២ នាក់ |
| ២៦-៤០ឆ្នាំ | ២ នាក់ |
| ៤១-៦០ឆ្នាំ | ៤ នាក់ |

## ៣. ការរកឃើញសំខាន់ៗ

ក្នុងជីវភាពប្រចាំថ្ងៃ ស្រ្តីទាំងនោះបានជួបបញ្ហាប្រឈមជាច្រើនរួមមាន កង្វះអាហារប្រចាំថ្ងៃ ប្រាក់ចំណូលមិនទៀងទាត់ មានជម្ងឺ បញ្ហាសុខភាពផ្លូវចិត្ត កង្វះខាតសេវាមូលដ្ឋាន ការរើសអើង អំពើហិង្សាក្នុងគ្រួសារ (អំពើហិង្សាលើរាងកាយ និងផ្លូវចិត្ត) និងការព្រួយបារម្ភពីការបណ្តេញចេញដោយបង្ខំ។

### ប្រាក់ចំណូលមិនទៀងទាត់ និងកង្វះអាហារប្រចាំថ្ងៃ

ស្រ្តីភាគច្រើនប្រកបមុខរបរដូចជា លក់ដូរនៅផ្ទះ លក់នំប៉័ង ជាងកាត់ដេរ ស៊ីឈ្នួល បេះត្រកួន កម្មករសំណង់ និងអ្នកគ្មានការងារធ្វើ (មនុស្សចាស់ និងអ្នកមានជម្ងឺ)។ តាមរយៈមុខរបរទាំងនោះអាត្រាប្រាក់ចំណូលរបស់ពួកគាត់ចន្លោះពី ១៦ម៉ឺនរៀល (ប្រហែល ៤០ដុល្លារអាមេរិក) ទៅ ៧៦ម៉ឺនរៀល (ប្រហែល ១៩០ដុល្លារអាមេរិក) ក្នុងមួយខែ។ ប្រាក់ឈ្នួលអប្បបរមារបស់កម្មករនៅក្នុងឧស្សាហកម្មកាត់ដេរ និងស្បែកជើងនៅក្នុងប្រទេសកម្ពុជាមានចំនួន ៧២ម៉ឺន៨ពាន់រៀល (ប្រហែល ១៨២ ដុល្លារអាមេរិក) ក្នុងមួយខែចាប់ពី ខែមករា ឆ្នាំ២០១៩។[1]



ស្រ្តីម្នាក់ដែលរកប្រាក់ចំណូលជាមធ្យមប្រចាំខែចំនួន១៦ម៉ឺនរៀល (ប្រហែល ៤០ដុល្លារអាមេរិក) ជាស្រ្តីមេម៉ាយដែលមានអាយុ៥៩ឆ្នាំ រស់នៅម្នាក់ឯងលើសំណង់អាគារបាក់បែកចាស់ទ្រុឌទ្រោមដោយ ខ្វះអគ្គីសនី ខ្វះទឹកប្រើប្រាស់ និងអាហារមិនគ្រប់គ្រាន់ ព្រោះប្រាក់ចំណូលរបស់គាត់ទាប។ រដ្ឋមិនបានតភ្ជាប់អគ្គីសនីដល់ផ្ទះរបស់គាត់ទេ ដែលជាមូលហេតុធ្វើឱ្យគាត់ប្រើប្រាស់អគ្គីសនីពីឯកជនដែលមានតម្លៃថ្លៃ។ សព្វថ្ងៃគាត់កំពុងមានជំងឺហើយពុំមានលទ្ធភាពនឹងទិញថ្នាំសម្រាប់ព្យាបាលនោះទេ។

ស្ទើរតែទាំងអស់នៃគ្រួសារស្រ្តីដែលបានផ្តល់បទសម្ភាស មានការលំបាកក្នុងការហូបចុកយ៉ាងខ្លាំង។ ស្រ្តីដែលជាម្តាយដែលទទួលខុសត្រូវការងារទាំងក្នុង និងក្រៅផ្ទះបាននិយាយថា គាត់ត្រូវចំណាយ

---

[1] យោងតាមប្រភព៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ឆ្នាំ២០១៩),ស្តីពីប្រកាសស្តីពីការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង,
http://www.mlvt.gov.kh/index.php?option=com_k2&view=item&id=1011

ប្រាក់ចំនួនដល់ទៅ៥ម៉ឺនរៀល (ប្រហែល ១២.៥០ដុល្លារអាមេរិក) សម្រាប់ផ្គត់ផ្គង់លើថ្លៃអាហារ និងថ្លៃកូនរៀនចំនួនបួននាក់ជារៀងរាល់ថ្ងៃ។ ស្ត្រីខាងលើបានបន្តទៀតថា ស្វាមីរបស់គាត់មានមុខរបរជាកម្មករលីសែងប្រើកំលាំងដោយទទួលបានកម្រៃតែ ៥ម៉ឺនរៀល (ប្រហែល ១២.៥០ដុល្លារអាមេរិក) ប៉ុណ្ណោះក្នុងមួយថ្ងៃ ដោយការងារនោះធ្វើតែ ២០ ទៅ២៥ថ្ងៃប៉ុណ្ណោះក្នុងមួយខែ។ ដោយសារតែប្រាក់ចំណូលរបស់គាត់មានកំណត់ គាត់មិនអាចចំណាយទិញអ្វីបានទេ ក្រៅពីចំណាយលើអាហារ និងការសិក្សារបស់កូន ដូច្នេះទើបគ្រួសាររបស់គាត់មានការខ្វះខាត។ *គាត់បន្តថា" នៅក្នុងគ្រួសាររបស់ខ្ញុំប្រសិនបើស្វាមីខ្ញុំឈឺនោះគ្រួសារទាំងមូលនឹងមិនមានលទ្ធភាពដើម្បីទិញម្ហូបអាហារ និងឱ្យកូនទៅរៀនសូត្របាននោះទេ"។*

## សុខភាពរាងកាយ

ពាក់កណ្តាលនៃស្ត្រីដែលរស់នៅក្នុងសហគមន៍ក្រីក្រទាំងនោះ បានជួបបញ្ហាទឹកលិចនៅច្រកចេញចូលក្នុងសហគមន៍របស់ពួកគាត់។ ទឹកជំនន់មានលាយឡំជាមួយនឹងទឹកស្អុយ សំរាមដែលបណ្តាលឱ្យមានទឹកកខ្វក់ដក់ក្នុងសហគមន៍ជាច្រើនសប្តាហ៍បានជះឥទ្ធិពលយ៉ាងខ្លាំងចំពោះស្ត្រី និងកុមារដូចជា ទឹកស៊ីដៃជើង រាគរុស គ្រុនឈាមជាដើម ប្រសិនបើការលិចទឹកនោះមានរយៈពេលយូរ (មួយថ្ងៃឬពីរថ្ងៃ)។ ស្ត្រីក្រីក្រទទួលរងផលប៉ះពាល់ជាងបុរស ដោយសារតែពួកគាត់មានតួនាទីជាអ្នកថែទាំផ្ទះសម្បែង មើលថែកូនជួយចម្លងកូនតូចៗចេញចូលពីទឹកក្នុងសហគមន៍ និងធ្វើដំណើរច្រើនដងតាមទឹកដែលជន់លិចដោយមិនបានជិះម៉ូតូនោះទេ (ផ្ទុយទៅវិញ បុរសធ្វើដំណើរតែពីរដងប៉ុណ្ណោះក្នុងមួយថ្ងៃ ដើម្បីចេញទៅធ្វើការងារនៅខាងក្រៅសហគមន៍ និងប្រើប្រាស់ម៉ូតូ)។

ស្ត្រីក្រីក្រចំនួន២នាក់បានប្រាប់ពីបញ្ហាសុខភាព និងសុវត្ថិភាពរបស់ពួកគាត់ ដែលកើតឡើងដោយសារទឹកជំនន់នៅក្នុងសហគមន៍។ ស្ត្រីម្នាក់បានលើកឡើងថា គាត់ពិបាកចិត្តខ្លាំងណាស់ដែលគាត់ត្រូវដើរឆ្លងកាត់ទឹកកខ្វក់ពី ៤ទៅ៥ដងក្នុងមួយថ្ងៃដើម្បីជួយចម្លងកូនរបស់គាត់ទៅនឹងចេញពីសាលារៀន។ កាលពីមុនគាត់ធ្លាប់ថ្នមកូនទូកពីដបទឹកដ៏រ និងចម្លងកូនទៅនឹងចេញពីសាលារៀន ពេលនោះគាត់ត្រូវដើរឆ្លងកាត់ទឹកដែលជន់លិច។ ក្រោយមកគាត់បានឆ្លងជំងឺដែលមិនអាចទៅធ្វើការងារនៅខាងក្រៅបាន។ ទោះបីជាយ៉ាងក៏ដោយ ក្រោយពីមានជម្ងឺគាត់មិនបានទៅស្វែងរកការព្យាបាលឡើយ ដោយសារវាមានតម្លៃថ្លៃ ហើយគាត់ចង់ផ្តល់ការចំណាយសម្រាប់ការសិក្សាដល់កូនៗរបស់គាត់។ ម៉្យាងវិញទៀតក្នុងករណីមួយដែលមានជំងឺទាំងប្រពន្ធ និងប្តីភាគីខាងប្តីតែងតែទៅស្វែងរកការព្យាបាល រីឯប្រពន្ធវិញមិនបានទៅស្វែងរកការព្យាបាលនោះទេ។ គាត់បានពន្យល់ថា គាត់មិនសូវខ្វល់អំពីសុខភាពរបស់គាត់ច្រើនដូចប្តីរបស់គាត់នោះទេ ព្រោះគាត់គិតថាប្តីរបស់គាត់ជាបុគ្គលសំខាន់ក្នុងការស្វែងរកចំណូលសម្រាប់ផ្គត់ផ្គង់នៅក្នុងគ្រួសារ។ ស្ត្រីដដែលបានបន្តទៀតថា "បញ្ហាសុខភាពជារឿង "បន្ទាប់- បន្សំ" "មិនមែនជារឿងចម្បង" "មិនសូវសំខាន់" ដែលត្រូវគិតនោះទេ។ ជាធម្មតាគាត់មិនបានចាត់អាទិភាពក្នុងស្វែងរកការព្យាបាលថែទាំសុភាពនោះទេ ដោយសារតែការព្រួយបារម្ភផ្នែកហិរញ្ញវត្ថុសម្រាប់ផ្គត់ផ្គង់ក្នុងគ្រួសារ។ ម៉្យាងវិញទៀត ពួកគាត់ពុំមានពេលដើម្បីមើលថែខ្លួននោះទេ ដោយសារពួកគាត់រវល់ការងារច្រើនដែលត្រូវមើលថែកូន និងការទទួលខុសត្រូវផ្សេងៗក្នុងផ្ទះ។

## សុខភាពផ្លូវចិត្ត

មានស្ត្រីក្រីក្រចំនួន៦នាក់ក្នុងចំណោមស្ត្រីដែលផ្តល់បទសម្ភាស មានបញ្ហាសុខភាពផ្លូវចិត្តធ្ងន់ធ្ងរ តាមរយៈការប្រឈមទៅនឹងបញ្ហានានាក្នុងជីវភាពប្រចាំថ្ងៃ និងការព្រួយបារម្ភយ៉ាងខ្លាំងពីការបណ្តេញចេញពីលំនៅឋានរបស់ពួកគាត់ ហើយមានស្ត្រីតែម្នាក់ប៉ុណ្ណោះ ដែលបានទទួលការព្យាបាលខាងបញ្ហាផ្លូវចិត្តពីកម្មវិធីសុខភាពផ្លូវចិត្តដែលគាំទ្រពីអង្គការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានៅអង្គការចិត្តសង្គមអន្តរវប្បធម៌។ គាត់ក៏បានរៀបរាប់ទៀតថា ស្វាមីរបស់គាត់តែងតែមិនអនុញ្ញាតឱ្យគាត់ចូលរួមការងារតស៊ូមតិជាមួយស្ថាប័នផ្សេងៗ ព្រោះស្វាមីរបស់គាត់យល់ថាការចូលរួមក្នុងសកម្មភាពទាំងនោះ វាមិនទទួលបានផលវិជ្ជមានទេ ផ្ទុយទៅវិញមានតែទទួលបានការមិនពេញចិត្តពីសមាជិកសហគមន៍គ្នាឯង និងទទួលរងការគំរាមកំហែងពីអាជ្ញាធរ។ គាត់ចង់ឱ្យនៅស្ងៀមស្ងាត់រង់ចាំការដោះស្រាយពីអាជ្ញាធរមូលដ្ឋានទៅវាប្រសើរជាង។

ស្ត្រីរូបនេះមានបញ្ហាផ្លូវចិត្ត ក្រោយពីទទួលបានព័ត៌មានពីការបណ្តេញចេញពីផ្ទះរបស់គាត់។ គាត់ចាប់ផ្តើមចូលរួមសកម្មភាពតស៊ូមតិនានាជាមួយសហគមន៍ ដោយស្វាមីរបស់គាត់ជាមន្ត្រីយោធាមានការរវល់នឹងការងារមិនមានពេលគ្រប់គ្រាន់ ក្នុងការតស៊ូមតិឬដំណើរការនៃការបណ្តេញចេញនេះទេ ដូច្នេះហើយការងារតស៊ូមតិពីការបណ្តេញចេញ ជាទំនួលខុសត្រូវរបស់ស្ត្រីក្នុងការការពារគ្រួសារពីការបណ្តេញចេញ។ គាត់បានទំលាក់ចោលការងារដើម្បីថែរក្សាផ្ទះសម្បែង និងជាសកម្មជនការពារដីធ្លីម្នាក់។ ក្រោយពីបានចូលរួមធ្វើការងារតស៊ូមតិគាត់បានជួបបញ្ហាជាច្រើន រួមមានទំនាស់ក្នុងគ្រួសារ ការមិនចុះសម្រុងជាមួយស្វាមី (ស្វាមីរបស់គាត់តែងតែហាមឃាត់មិនឱ្យចូលរួមសកម្មភាពនានា) ការគំរាមកំហែងពីសំណាក់អាជ្ញាធរ និងការច្រណែនពីសមាជិកសហគមន៍ ដោយសារតែគាត់បានទទួលវគ្គបណ្តុះបណ្តាលពីអង្គការ។ ឆ្លងកាត់បទពិសោធន៍នេះធ្វើឱ្យគាត់ទទួលរងការឈឺចាប់ផ្លូវចិត្ត និងស្ទាក់ស្ទើរក្នុងការបន្តការងារតស៊ូមតិ។

## ការរើសអើង

ស្ត្រីដែលបានផ្តល់បទសម្ភាសភាគច្រើនបានលើកឡើងថា ពួកគាត់តែងតែទទួលរងនូវការរើសអើងពីអាជ្ញាធរមូលដ្ឋានក្នុងការងាររដ្ឋបាល ហើយតែងតែមិនបានទទួលព័ត៌មានដែលទាក់ទងនៅថ្នាក់មូលដ្ឋានរបស់ពួកគាត់។ ក្នុងករណីនេះ ស្ត្រីម្នាក់ដែលកំពុងរស់នៅក្នុងសហគមន៍ក្រីក្របានលើកឡើងថា "ខ្ញុំមិនដែលឃើញអាជ្ញាធរចុះមកសហគមន៍ទេ លើកលែងតែកំឡុងពេល មុនបោះឆ្នោតប៉ុន្តែក្រោយមកខ្ញុំមិនបានឃើញនោះទេ[២]"។ លើសពីនេះទៅទៀត ប្រជាពលរដ្ឋដែលរស់នៅខាងក្រៅសហគមន៍ក៏បានរើសអើងដល់ប្រជាសហគមន៍ផងដែរ។ ពួកគាត់បន្តថា ពួកគេតែងតែបង្ហាញនូវកាយវិការស្អប់ខ្ពើមមិនចង់និយាយជាមួយឬមិនចង់នៅជិត និងមិនចង់មានទំនាក់ទំនងជាមួយសហគមន៍ និងមិនអនុញ្ញាតឱ្យកូនៗរបស់ពួកគេមកលេងជាមួយក្មេងៗ ដោយគាត់គិតថាតំបន់នេះពោរពេញទៅដោយអ្នកប្រើប្រាស់

---

[២]អាជ្ញាធរបានចុះមកផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋនាំគ្នាទៅចុះឈ្មោះបោះឆ្នោតឃុំសង្កាត់ក្នុងឆ្នាំ២០១៧។ យោងតាមប្រភព៖ អង្គការសមាគមន៍ធាងត្នោត(២០១៦), របាយការណ៍អង្គការសមាគមធាងត្នោតបានរកឃើញថាប្រជាពលរដ្ឋ៦២%យល់ដឹងពីរបៀបចូលរួមបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០១៧, https://drive.google.com/file/d/0B59kYBxb99IoZkVHVWhzNDFTV3M/view

គ្រឿងញៀន និងអសុវត្ថិភាព។ ជានិច្ចជាកាលស្ត្រីទទួលបានអារម្មណ៍រើសអើងច្រើនជាងបុរស ដោយសារស្ត្រីក្នុងសហគមន៍ទាំងនោះ បានប្រកបមុខរបរលក់ដូរបន្តិចបន្តួច និងមើលថែទាំកូននៅផ្ទះ។ ចំណែកឯបុរសវិញ មិនមានអារម្មណ៍ទទួលការរើសអើងទេ ព្រោះបុរសភាគច្រើនចេញទៅប្រកបមុខរបរនៅខាងក្រៅសហគមន៍។ គាត់បន្តថា "ពួកគាត់ចេញទៅប្រកបរបរ ឬការងារតាំងពីព្រឹកហើយត្រឡប់មកវិញនៅពេលល្ងាច"។

ស្ត្រីម្នាក់ដែលបានក្លាយជាតំណាងសហគមន៍ តាមរយៈការជ្រើសរើសរបស់ប្រជាសហគមន៍ គាត់បានទទួលរងនូវការរើសអើងពីសំណាក់អាជ្ញាធរមូលដ្ឋាន នៅចំពោះមុខសាធារណជនខណៈពេលចូលរួមវេទិកាសាធារណៈមួយដែលបានរៀបចំដោយលោកចៅសង្កាត់។ លោកចៅសង្កាត់បានមានប្រសាសន៍ថា "ខ្ញុំមិនទទួលស្គាល់ស្ត្រីម្នាក់នេះ ជាអ្នកតំណាងឬជាប្រធានសហគមន៍នេះទេ ខ្ញុំបានជ្រើសរើសប្រធានសហគមន៍ម្នាក់ជាបុរសមកពីសហគមន៍មួយនេះ ហើយខ្ញុំមិនចង់ធ្វើការជាមួយស្ត្រីដែលរញ៉េរញ៉ៃនោះទេ។ ក្រោយពីទំនាស់មួយនេះ ស្វាមីរបស់គាត់ចាប់ផ្តើមរារាំងនូវរាល់ការចូលរួមក្នុងសកម្មភាពសង្គម ផ្សេងៗទាំងនៅក្នុងសហគមន៍ និងខាងក្រៅសហគមន៍ពីព្រោះស្វាមីរបស់គាត់បារម្ភនាំឱ្យមានបញ្ហាដល់គ្រួសារ។ ទស្សនាវដ្តីមួយរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានលើកឡើងថា "ស្ត្រីគឺជាចលករយ៉ាងសំខាន់ក្នុងការចូលរួមអភិវឌ្ឍន៍ជាតិលើគ្រប់វិស័យ "។[៣]

ទីចុងក្រោយស្ត្រីទាំងអស់ក្នុងសហគមន៍មានការខ្វះខាតហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដូចជាភ្លើងបំភ្លឺផ្លូវ។ យោងតាមទិន្នន័យរបស់អង្គការសមាគមចាងឆ្នោតសហគមន៍ក្រីក្រចំនួន២៤៣ (៨៨ភាគរយ) នៃ២៧៧ ទីតាំងនៃសហគមន៍ក្រីក្រគ្មានភ្លើងបំភ្លឺផ្លូវ។ កង្វះភ្លើងបំភ្លឺផ្លូវអាចបង្កើតឱ្យមានការរំលោភបំពាននានា ជាពិសេសមកលើស្ត្រីដែលធ្វើការងារនៅខាងក្រៅហើយត្រឡប់មកវិញនៅពេលយប់។ ការរំលោភសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស់ និងចោរកម្មកើតឡើងដោយសារកង្វះភ្លើងបំភ្លឺផ្លូវ។

### អំពើហិង្សាក្នុងគ្រួសារ

ការស្រាវជ្រាវបានរកឃើញថា មានស្ត្រីចំនួន២នាក់ដែលធ្លាប់បានទទួលរងនូវអំពើហិង្សាលើរូបរាងកាយ។ ស្ត្រីទី១បានប្រាប់ថា គាត់បានទទួលរងនូវអំពើហិង្សាយ៉ាងធ្ងន់ធ្ងរស្ទើរតែបាត់បង់ជីវិតកូនពីសំណាក់ស្វាមីរបស់គាត់។ ក្រោយពីបានកើតមានអំពើហិង្សានេះគាត់ក៏បានលែងលះជាមួយអតីតស្វាមីរបស់គាត់។ ស្ត្រីទី២បាននិយាយថា អំពើហិង្សាក្នុងគ្រួសាររបស់គាត់កើតឡើងដោយសារតែការទាស់សំដីគ្នាពីការរកប្រាក់ចំណូលផ្គត់ផ្គង់ក្នុងគ្រួសារ។ ស្វាមីរបស់គាត់ចូលចិត្តផឹកស្រាហើយតែងតែវាយធ្វើបាបគាត់ជារឿយៗ។ កាន់តែពិបាកជាងនេះគឺគាត់បានរស់នៅក្នុងផ្ទះបងប្អូនសាច់ថ្លៃពេលមានបញ្ហាម្តងៗគ្មានអ្នកជួយដោះស្រាយឬគាំទ្រនោះទេ។

[៣] យោងតាមប្រភព៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ(២០១៥),ស្តីពីទស្សនាវដ្តការងារកម្ពុជា៖ http://www.mlvt.gov.kh/index.php?option=com_k2&view=item&id=246B6&Itemid=203&lang=en

**ការព្រួយបារម្ភពីការបណ្តេញចេញពីលំនៅឋាន**



ស្ត្រីក្រីក្រភាគច្រើនក្នុងសហគមន៍ដែលបានផ្តល់បទសម្ភាស កំពុងរស់នៅក្នុងសហគមន៍ក្រីក្រ និងមានបញ្ហាជាមួយអាជ្ញាធរទាក់ទងនឹងបញ្ហាសិទ្ធិដីធ្លី និងមានទំនាស់ជាមួយអាជ្ញាធរអំពីសិទ្ធិដីធ្លី និងលំនៅឋានរបស់ពួកគាត់។ បញ្ហាខាងលើនេះបានធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្តស្ត្រី និងបង្កឱ្យមានភាពមិនចុះសម្រុង ជាមួយក្រុមគ្រួសារហើយនៅក្នុងនោះស្ត្រីដែលមានតួនាទីជាប្រធាន ឬតំណាងសហគមន៍ចំនួន៤នាក់ផងដែរ។ ថ្វីត្បិតតែស្ត្រីភាគច្រើនមិនមែនជាមេគ្រួសារ តែស្ត្រីទាំងនោះក៏ទទួលបន្ទុករ៉ាប់រងការងារច្រើននៅក្នុងគ្រួសារ និងដឹកនាំការងារសហគមន៍ដើម្បីទាមទារសិទ្ធិដីធ្លី និងលំនៅឋានរបស់ពួកគាត់ដែរ។ ពួកគាត់បានលើកឡើងថា អ្វីដែលពួកគាត់ភ័យខ្លាចបំផុតគឺការបណ្តេញចេញដោយបង្ខំ ហើយវាក៏ជាបញ្ហាចម្បងដែលត្រូវការដោះស្រាយដែរ។

## ៤. សេចក្តីសន្និដ្ឋាន

យោងតាមការរកឃើញខាងលើយើងអាចធ្វើការសន្និដ្ឋានថាៈ

- ស្ត្រីអាចទទួលរងនូវផលប៉ះពាល់ពីជីវភាពក្រីក្រខ្លាំងបើធៀបទៅនឹងបុរស ដោយសារស្ត្រីគិតគូរពីក្នុងសហគមន៍ច្រើន ពួកគាត់ប្រឈមនឹងជម្ងឺ ការរើសអើងច្រើន ការផាត់ពួកគាត់ចេញពីការងារ និងពីសាលារៀន។
- ស្ត្រីក្លាយជាតួអង្គសំខាន់ ក្នុងការដឹកនាំសហគមន៍របស់ពួកគាត់ដើម្បីតស៊ូមតិទាមទារសិទ្ធិដីធ្លី និងសិទ្ធិលំនៅឋាន។
- ស្ត្រីមិនត្រូវបានផ្តល់នូវគុណតម្លៃក្នុងការសម្រេចចិត្តថាតើ ស្វាមី ឬភរិយាដែលគួរតែទទួលបានការព្យាបាលព្រោះតែសេដ្ឋកិច្ចក្នុងគ្រួសារពឹងផ្អែកលើប្រាក់ចំណូលរបស់ស្វាមី សម្រាប់ស្ត្រីត្រូវមើលថែទាំកូន ចំអិនម្ហូបអាហារ សម្អាតផ្ទះសម្បែង និងការទទួលខុសត្រូវផ្សេងទៀតក្នុងគ្រួសារ។
- បញ្ហាជាច្រើនដែលស្ត្រីប្រឈមមានដូចជា ខ្វះហេដ្ឋារចនាសម្ព័ន្ធ ខ្វះការចូលរួមក្នុងវិស័យនយោបាយ ដែលជាទំនួលខុសត្រូវរបស់រដ្ឋ និងជាបញ្ហាសិទ្ធិមនុស្សដែល ប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិស្ត្រី។

## ៥. អនុសាសន៍

អាជ្ញាធរគួរតែធ្វើការពិនិត្យមើលរាល់តម្រូវការសេវាមូលដ្ឋានក្នុងសហគមន៍ក្រីក្រ ដើម្បីធានាថាប្រជាពលរដ្ឋរស់នៅប្រកបដោយភាពសុខដុមរមនា និងផ្តល់ការគាំទ្រដល់សហគមន៍ទាំងនោះ ដែលជាការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល។

- អាជ្ញាធរគួរតែផ្តល់ប្លង់កម្មសិទ្ធិស្របច្បាប់ដល់ប្រជាសហគមន៍ក្រីក្រដើម្បីបង្កើនសុវត្ថិភាព និងជម្រុញលើកទឹកចិត្តឱ្យបន្តរស់នៅក្នុងជីវភាពមួយសមរម្យ និងលំនៅឋានសមរម្យ។
- សម្រាប់សហគមន៍គួរតែលើកកម្ពស់ស្ត្រីក្នុងការចូលរួមសម្រេចចិត្តលើការងារសង្គមផ្សេងៗដើម្បីជម្រុញឱ្យទទួលបានសិទ្ធិស្មើគ្នារវាងស្ត្រី និងបុរស។
- អាជ្ញាធរមូលដ្ឋានចូលរួម កាត់បន្ថយអំពើហិ ង្សាក្នុងគ្រួសារ ។
- ផ្តល់ការលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធដើម្បីការពារស្ត្រីពីអំពើហិង្សាជាពិសេសការផ្តល់ ភ្លើងបំភ្លឺផ្លូវ។

# បញ្ហាប្រឈមនានា



ទឹកលិចផ្លូវចេញចូលក្នុងសហគមន៍



ទឹកលិចផ្លូវចេញចូលក្នុងសហគមន៍



ផ្ទះបាយរបស់ប្រជាសហគមន៍



ស្ថានភាពបន្ទប់គេងរបស់ប្រជាសហគមន៍

# រូបភាពស្អាត



សួនច្បារខាងក្រៅផ្ទះ ( លេខ ៣ ត្រូវបានបាញ់ថ្នាំដោយអាជ្ញាធរ និងជាសញ្ញាមួយបង្ហាញថាសហគមន៍ អាចត្រូវគេបណ្តេញចេញ)



ស្ពានឆ្លងទឹកក្នុងសហគមន៍

សមាគមធាងត្នោត

Sahmakum Teang Tnaut- a Cambodian Urban NGO

T: 023 555 1964
W: http://teangtnaut.org/
UV: https://urbanvoicecambodia.net/
F: https://www.facebook.com/teangtnaut/